**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស**
**លេខ:** ០០៦/១៦ សជណ.ពព.ម

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
## ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥

ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ២០១៥ វេលាម៉ោង៨ និង៣០នាទី នៅវិមានសន្តិភាព មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ** **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លង៖

**១- សេចក្តីព្រាងច្បាប់ ស្តីពីស្ថិតិ**

**២- សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០១៦-២០១៨**

**៣- បញ្ហាផ្សេងៗ៖**

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័ត៖

**១- សេចក្តីព្រាងច្បាប់ ស្តីពីស្ថិតិ**

កន្លងមកច្បាប់ស្តីពីស្ថិតិ ឆ្នាំ២០០៥ បានផ្តល់មូលដ្ឋានគតិយុត្តប្រកបដោយសក្តានុពល អនុញ្ញាតឲ្យវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការអាចប្រតិបត្តិការយ៉ាងទូលំទូលាយពេញទូទាំងប្រទេស ក្នុងការផលិតទិន្នន័យស្ថិតិស្ទើរគ្រប់វិស័យ តាមវិធីសាស្ត្របច្ចេកទេសទំនើប គឺការធ្វើជំរឿន និងការធ្វើអង្កេតដើម្បីទទួលបានទិន្នន័យស្ថិតិត្រឹមត្រូវ ជឿទុកចិត្តបាន និងទាន់ពេលវេលាជូនអ្នកប្រើប្រាស់ជាតិ និងអន្តរជាតិ ជាពិសេសអ្នករៀបចំផែនការ

គោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព សម្រេចបានតាមគោលដៅជាក់លាក់។

ផ្អែកតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីស្ថិតិឆ្នាំ២០០៥ វិទ្យាស្ថានជាតិស្ថិតិបានអនុវត្ត និងបំពេញភារកិច្ចស្ទើរតែគ្រប់ទាំងអស់ដូចមានចែងក្នុងច្បាប់ ឧទាហរណ៍: ដូចជាជំរឿនដែលជាការងារធំ ហើយសំខាន់ជាងគេបំផុត ក្នុងច្បាប់ស្តីពីស្ថិតិបានចែងថា វិទ្យាស្ថានជាតិស្ថិតិត្រូវអនុវត្តជំរឿនចំនួន៣ មានជំរឿនប្រជាជន ជំរឿនកសិកម្ម និងជំរឿនសេដ្ឋកិច្ច។ មកដល់ពេលនេះ វិទ្យាស្ថានស្ថិតិបានបំពេញការងារដ៏ធំជាប្រវត្តិសាស្ត្រនេះ ប្រកបដោយជោគជ័យឆ្លើយតបបានគ្រប់ភារកិច្ច និងបេសកកម្ម ដូចច្បាប់បានបញ្ញត្តិ គឺជំរឿនប្រជាជនឆ្នាំ១៩៩៨ ឆ្នាំ២០០៨ ជំរឿនសេដ្ឋកិច្ចឆ្នាំ២០១១ ជំរឿនកសិកម្មឆ្នាំ២០១៣ កំពុងតែដំណើរការ ហើយលទ្ធផលចុងក្រោយ នឹងប្រកាសជាផ្លូវការនាពេលអនាគតដ៏ខ្លីខាងមុខនេះ។

ក្នុងយុគសម័យនៃការរីកចំរើនផ្នែកព័ត៌មានវិទ្យា ព័ត៌មានទិន្នន័យស្ថិតិត្រូវបានឲ្យតម្លៃខ្ពស់ ហើយបានក្លាយទៅជាឧបករណ៍ដ៏ចាំបាច់បំផុតសម្រាប់តាមដាន ត្រួតពិនិត្យវាយតម្លៃអំពីស្ថានភាពនៃការវិវឌ្ឍ សេដ្ឋកិច្ច សង្គមកិច្ច និងប្រជាសាស្ត្ររបស់ប្រទេសទាំងឡាយលើពិភពលោក។ ទោះបីជាសម្រេចបានសមិទ្ធផលយ៉ាងច្រើនដូចបានជំរាបជូនខាងលើក៏ដោយ ក៏នៅមានចំណុចខ្វះខាត និងភាពប្រឈមខ្លះដែលត្រូវតែពិនិត្យ និងដោះស្រាយក្នុងដំណាក់កាលនេះ និងសម្រាប់អនាគតតាមរយៈការកែសម្រួលច្បាប់ស្តីពីស្ថិតិឡើងវិញ។

សេចក្តីព្រាងច្បាប់ស្តីពីស្ថិតិថ្មីនេះ ក៏ត្រូវបានតាក់តែងឡើងដោយក្រសួងផែនការ និងមានកិច្ចសហប្រតិបត្តិការ ជាមួយនឹងបណ្តាប្រទេសនានាដែលមានប្រព័ន្ធស្ថិតិរឹងមាំ រីកចំរើន ពិសេសគឺការផ្តល់អនុសាសន៍របស់អ្នកជំនាញការស្ថិតិអង្គការ Paris21 (សាធារណរដ្ឋបារាំង) ដែលធ្លាប់មានបទពិសោធន៍យ៉ាងច្រើន លើជំនួយបច្ចេកទេសក្នុងការធ្វើបទប្បញ្ញត្តិស្ថិតិ នៅក្នុងពិភពលោក។

សេចក្តីព្រាងច្បាប់ស្តីពីស្ថិតិថ្មីនេះ មាន ១០ជំពូក និងមាន ៣៨មាត្រា មានវិសាលភាពអនុវត្តលើរាល់សកម្មភាពស្ថិតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**២- សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០១៦-២០១៨**

ស្ថានភាពសេដ្ឋកិច្ចកម្ពុជាមានភាពល្អប្រសើរ ហើយកំពុងស្ថិតនៅលើគន្លងនៃកំណើនខ្ពស់ប្រកបដោយចីរភាពក្នុងរយៈពេលមធ្យម ទោះបីកំណើនសេដ្ឋកិច្ចពិភពលោកនៅមានភាព

ផុយស្រួយ ហើយស្ថានការណ៍នយោបាយនៃតំបន់មួយចំនួននៅក្នុងពិភពលោក កំពុងស្ថិតក្នុងភាពមិនច្បាស់លាស់ក៏ដោយ។ ជាលទ្ធផល កំណើនសេដ្ឋកិច្ចកម្ពុជាសម្រេចបានក្នុងរង្វង់ ៧% ក្នុង១ឆ្នាំៗ។

ការអនុវត្តថវិកាឆ្នាំ២០១៤ បានបង្ហាញឲ្យឃើញនូវការកែទម្រង់ស៊ីជម្រៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងនោះរួមមាន ការដំឡើងបៀវត្សរ៍ជូនមន្ត្រីរាជការ យោធិន នគរបាលជាតិ និងនិវត្តជន ជាពិសេសជូនគ្រូបង្រៀន និងគ្រូពេទ្យ ទន្ទឹមនឹងការធ្វើកំណែទម្រង់ប្រព័ន្ធបៀវត្សរ៍ និងប្រព័ន្ធរដ្ឋបាលសាធារណៈ ហើយប្រការដែលសំខាន់បំផុត គឺការធានាបាននូវការបើកប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការបានទាន់ពេលវេលាក្នុងសប្តាហ៍ទី៤ នៃខែនីមួយៗ។

សម្រាប់ការរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល២០១៦-២០១៨ ក្រសួងផែនការបានបន្តធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មាធិការនីតិសម្បទាន និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីឈានទៅសម្រេចបាននូវសុខដុមនីយកម្ម ការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ និងដើម្បីពង្រឹងយន្តការស្ថាប័ននៃការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព។

គោលបំណងសំខាន់នៃកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.) ៣ឆ្នាំរំកិល ២០១៦-២០១៨ គឺធ្វើការបង្ហាញពីទិន្នន័យគម្រោងវិនិយោគដែលមានអាទិភាពខ្ពស់របស់ក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា ដែលជាគោលនយោបាយមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តគោលនយោបាយដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៤-២០១៨ ជាផែនការដែលបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិកាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤។

កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០១៦-២០១៨ ដែលមានតម្លៃសរុបប្រចាំឆ្នាំប្រមាណ ១៨០០លានដុល្លារអាមេរិក ត្រូវបានរៀបចំឡើងដោយផ្អែកលើតម្រូវការចំណាយសរុប សម្រាប់ការអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ដើម្បីឲ្យបានស្របតាមស្ថានភាពជាក់ស្តែងនៃការប្រែប្រួលថ្លៃទំនិញ និងអតិផរណា ហើយក៏ផ្អែកលើបរិមាណហិរញ្ញប្បទានសហប្រតិបត្តិការដែលដៃគូអភិវឌ្ឍធ្លាប់បានសន្យា។

ក្នុងចំនួនគម្រោងសរុប ៤៩៥ គម្រោងនៃ កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំ រំកិល ២០១៦-២០១៨ នេះមានចំនួន១៦៤ គម្រោង ជាគម្រោងកំពុងដំណើរការដែលត្រូវការទុន ចំនួន ៣១៦៩ លានដុល្លារអាមេរិក និងចំនួន ៣៣១ គម្រោងដែលត្រូវដាក់ឲ្យអនុវត្តក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិត្រូវការទុនចំនួន ២៤០១លានដុល្លារអាមេរិក។

## ៣- **បញ្ហាផ្សេងៗ៖**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានក្រើនរំលឹកជាថ្មីម្តងទៀតដល់កង កំលាំងប្រដាប់អាវុធ នរគបាល និងយោធា អាជ្ញាធរដែនដី រាជធានី ខេត្តត្រូវខិតខំពង្រឹង សន្តិសុខ សណ្តាប់ធ្នាប់សង្គម ធានាសុវត្ថិភាពដល់ប្រជាពលរដ្ឋ ភ្ញៀវទេសចរ វិនិយោគិន ការពារព្រៃឈើ បរិស្ថាន ធនធានរ៉ែ ពិសេសចូលរួមជាមួយសមត្ថកិច្ចគយ ពន្ធដារ ក្នុងការ ប្រមូលចំណូលថវិកាជាតិ ។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១១ និង១០នាទី។

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥៧